# លិខិតចំហ
## របស់សមាជិកព្រឹទ្ធសភា គង់ គាំ

អតីតសមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឆ្នាំ១៩៨៥-១៩៩២ និងអតីតឯកអគ្គរដ្ឋទូតរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម នៅទីក្រុងហាណូយឆ្នាំ១៩៨០-១៩៨២ អតីតរដ្ឋមន្ត្រីការបរទេសរដ្ឋកម្ពុជា ឆ្នាំ១៩៨៦-១៩៨៨ ខ្ញុំ **គង់ គាំ** បច្ចុប្បន្នអនុប្រធានគណបក្ស សម រង្ស៊ី និងសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា សូមបញ្ជាក់ចំពោះមតិជាតិ និងអន្តរជាតិអំពីដំណើរនយោបាយមួយចំនួននៅកម្ពុជាដូចតទៅ :

នៅក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ **សាធារណរដ្ឋប្រជាមានិតចិន** ជាមួយភាគីខ្មែរក្រហមរបស់ **ប៉ុលពត អៀងសារី ខៀវសំផន** ម្ខាង និងម្ខាងទៀត **សាធារណរដ្ឋសង្គមនិយមវៀតណាម** ជាមួយភាគីខ្មែរក្រហមរបស់ **ហេងសំរិន ជាស៊ីម ហ៊ុនសែន** សុទ្ធតែបានប្រើឯកសារ និងភាសាផ្លូវការថា អនុត្តរភាពវាតទីនិយមប្រទេសធំចិន ដែលមានប៉ុលពតជាកូនសំពាយ គឺជាអ្នកប្រព្រឹត្ត និងទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជា ផ្ទុយទៅវិញ ខ្មាំងយួនសន្ធិសម្ព័ន្ធស៊ីរ៉ូវងផ្ទៃក្នុង គឺជាអ្នកពង្រឹងពង្រីកគណបក្សប្រជាជនកម្ពុជា មានប្រភពពីបក្សកុម្មុយនិស្តឥណ្ឌូចិនរបស់មេកុម្មុយនិស្តយួនហូជីមិញ អោយសំរេចផែនការដាក់កម្ពុជា លាវ ជារដ្ឋសហព័ន្ធឥណ្ឌូចិនក្រោមឥទ្ធិពលរបស់វៀតណាមជានិច្ចនោះ ក៏បានកាប់សម្លាប់ផ្តួលរំលំខ្មែរក្រហមប្រឆាំង ដែលនៅទីបញ្ចប់មានការប្រើកំលាំងឈ្លានពាន កាន់កាប់ ត្រួតត្រាកម្ពុជា ហើយលើកបន្តុបខ្មែរក្រហមឧបករណ៍យ៉ាងចំហ អោយបន្តអំណាចរហូតមកដែរ ។

ជាអ្នកជាប់គុកឥតជញ្ជាំងក្នុងរបបប៉ុលពត១៧មេសា ជាអ្នកជាប់កំណែនយួនត្រួតត្រា៧មករា និងជាអ្នកស្ម័គ្រចិត្តធ្វើជាសាក្សីអោយតុលាការវិនិច្ឆ័យទោសមេខ្មែរក្រហមនៅពេលខាងមុខ ខ្ញុំយល់ស្រប និងគាំទ្រចំពោះបណ្តឹងរបស់មជ្ឈដ្ឋានទូទៅ ដែលចោទថា **ភាគីចិនកុម្មុយនិស្ត**ជាមួយខ្មែរក្រហមប៉ុលពត អៀងសារី ខៀវសំផន និង**ភាគីវៀតណាមកុម្មុយនិស្ត**ជាមួយខ្មែរក្រហមហេងសំរិន ជាស៊ីម ហ៊ុនសែន គឺជាស្ថាបត្យកររួមគ្នានៃវាលពិឃាត "**សាច់កប់១៧មេសា ឆ្អឹងគាស់៧មករា**" ជាហូរហែ តែថាសាធារណរដ្ឋសង្គមនិយមវៀតណាម និងគណបក្សប្រជាជនកម្ពុជា ដែលមានកំណើតពី **ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១**នោះ ពិតជាអ្នកទទួលខុសត្រូវដោយផ្ទាល់ និងវែងឆ្ងាយជាងគេ អំពីឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅកម្ពុជា ។

រហូតបច្ចុប្បន្ន យុទ្ធសាស្ត្រ និងនយោបាយរបស់គណបក្សប្រជាជនកម្ពុជា ដែលមានលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាបុរសខ្លាំងបានពង្រឹង និងបន្តការគ្រប់គ្រងដឹកនាំកម្ពុជា បែបឯកបក្សកាន់តែច្បាស់ឡើងៗ ។ ជំនួសការច្របាច់បញ្ចូលគ្នា គណបក្សហ៊្វុនស៊ិនប៉ិចបានបន្ទាបពីឋានៈជាដៃគូរមកដើរតួជាគណបក្សអ្នកនាំពាក្យអោយគណបក្សប្រជាជនកម្ពុជាដ៏ស្មោះត្រង់លិចលង់ងើបមិនរួច ។ ការបង្កើតច្បាប់ធម្មនុញ្ញបន្ថែម ដើម្បីពន្លឺតរដ្ឋសភា និងរដ្ឋាភិបាលកញ្ចប់ ហើយខិតខំរៀបចំរបបសភាភ្លោះ ដែលព្រឹទ្ធសភាគ្មានតួនាទី សិទ្ធិអំណាចអ្វីសោះ ដោយផាត់ ឬកំចាត់តួនាទីគណបក្សជំទាស់ដ៏សំខាន់ដែលមានអាសនៈនៅក្នុងរដ្ឋសភាតាមការបន្ថយកូរ៉ុម និងមិនអោយមានសមាសភាពក្នុងគណៈកម្មការជំនាញនានារបស់សភា រួមទាំងការប្រឌិតរឿងដើម្បីដកអភ័យឯកសិទ្ធិសមាជិករដ្ឋសភា ហើយចាប់ខ្លួនយ៉ាងកំរោលនោះ បញ្ជាក់ថា ទាំងរូបភាព ទាំងខ្លឹមសារ គឺប្រជាធិបតេយ្យនៅកម្ពុជាបានធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរ ។

អ្នកនយោបាយប្រជែងដែលមានប្រជាប្រិយភាពខ្លាំង មិនត្រឹមតែត្រូវស្លាប់ ត្រូវចាប់ដាក់គុកតាមការទាយទុកទេ ប៉ុន្តែអាចទទួលបណ្តាសារអោយរងគ្រោះថ្នាក់ផ្សេងៗ ដូចជា ត្រូវប្លន់សម្លាប់ (រន្ទះបាញ់) ក្រឡាប់ឡាន -ល- យ៉ាងទាន់ហន់ ឆុតឆាប់គ្រប់ទីកន្លែង ។ លោកហ៊ុនសែនច្រើនរំលឹកថា អ្នកប្រឆាំងគាត់បានស្លាប់ជាបន្តបន្ទាប់ឥតបាន

ផលឡើយ ហើយចំអកអោយលោកតាឡូមរីតថា អាចស្លាប់ទៅចាប់ជាតិថ្មី ហើយមកប្រឆាំងហ៊ុនសែនវិញបាន ។

វប្បធម៌និទណ្ឌភាព គឺឧក្រិដ្ឋជន ឃាតក ចេះតែរួចខ្លួនជានិច្ច ពិសេសការអត់អោនទោស និង ផ្តល់តំណែងថ្មីអោយខ្មែរក្រហមជាយុទ្ធមិត្តអតីតកាលរបស់មេដឹកនាំជាអតីតខ្មែរក្រហមកំពុងកាន់អំណាច ព្រមទាំងការយកលេសនេះលេសនោះមិនអស់មិនហើយ មិនអោយមានតុលាការស្តង់ដារអន្តរជាតិធ្វើការជំនុំជំរះទោសមេខ្មែរក្រហមនោះ គឺបញ្ជាក់ថា ខ្មែរក្រហម៧មករា និងខ្មែរក្រហម១៧មេសា គឺតែមួយ ។

អំពីបញ្ហាបូរណភាពទឹកដី បញ្ហាសេដ្ឋកិច្ច និងសង្គមកិច្ចសព្វថ្ងៃនៅកម្ពុជា គឺពោរពេញដោយភាពក្លែងបន្លំលំអតែសំបកក្រៅ ។

ព្រះមហាវីរក្សត្រ នរោត្តម សីហនុ ទទួលជាប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់កិច្ចការព្រំដែនបានបញ្ជាក់ច្បាស់ថា នៅសម័យសង្គមរាស្ត្រនិយម ដែលព្រះអង្គទទួលខុសត្រូវនោះ គ្មានខ្សែបន្ទាត់ព្រំដែនកម្ពុជាជាមួយប្រទេសជិតខាងណា ដែលមិនច្បាស់លាស់ត្រឹមត្រូវទេ ។ ការគូសព្រំដែនកម្ពុជាជាមួយប្រទេសជិតខាង និងការទទួលស្គាល់តំបន់សតាមព្រំដែន ដែលបរទេសប្រើប្រាស់បាន គឺជាការកាត់ដីខ្មែរទៅអោយបរទេសសុទ្ធសាធ ។

ក្រោមឥទ្ធិពលអ្នកនយោបាយដែលមានអំណាចខ្លាំង តុលាការ និងកម្លាំងប្រដាប់អាវុធតែងបំបាក់ និងបង្ក្រាបចំពោះប្រជាពលរដ្ឋដែលតវ៉ាចំពោះអំពើដកហូតដីធ្លីស្នាក់នៅ អំពើហ្លួងហែងដីធ្លីអាជីវកម្ម និងស្រែចំការទាំងឡាយ បិទសិទ្ធិនយោបាយរបស់ពលរដ្ឋ រំលោភបំពានលើសេរីភាពរបស់កម្មករ បំភិតបំភ័យមន្ត្រីរាជការ រារាំង និងកំចាត់កំចាយគ្រូបង្រៀនដែលទាមទារតំលើងប្រាក់ខែ-ល- ។ និយាយរួមរដ្ឋាភិបាលមិនអើពើយឺឆ្អាល ជួយសំរាលជីវភាពប្រចាំថ្ងៃរបស់អ្នកក្រីក្រ ដែលកាន់តែវេទនាដុនដាបខ្លាំងឡើង ដោយតម្លៃប្រេង តម្លៃទំនិញផ្សេងៗ និងការជំរិតអោយបង់ប្រាក់នានាជាច្រើនទៀតនោះសោះឡើយ ។

ប្រឈមមុខជាមួយវប្បធម៌និទណ្ឌភាព អភិបាលកិច្ចអាក្រក់ អំពើពុករលួយ និងអំពើអយុត្តិធម៌សង្គមគ្រប់បែបយ៉ាងនេះ ខ្ញុំ និងប្រជាពលរដ្ឋខ្មែរ សូមស្ថាប័នកំពូលរបស់ជាតិ ជាអាទិ ព្រះមហាក្សត្រ សភា និងរដ្ឋាភិបាលបង្កើនឆន្ទៈជួយជំរុញអោយកម្ពុជាមាននីតិរដ្ឋ អភិបាលកិច្ចល្អ កាត់បន្ថយភាពក្រីក្រអោយជាក់ស្តែង និងមានប្រសិទ្ធភាពជាបន្ទាន់ឡើង ។

ទន្ទឹមការខិតខំនៃស្ថាប័នកំពូលរបស់ជាតិ និងដំណើរការវិនិច្ឆ័យទោសមេខ្មែរក្រហមទាំងអស់នៅតុលាការ ចូរប្រជាពលរដ្ឋកម្ពុជារងគ្រោះទាំងក្រោមរបប១៧មេសា និង៧មករា ជួយខ្លួនដោយខ្លួនឯង គឺរួមកម្លាំងគ្នា ធ្វើការផ្លាស់ប្តូរមេដឹកនាំផ្តាច់ការពុករលួយ បង្កមហន្តរាយ បង្កើនភាពក្រីក្រដល់ប្រជាពលរដ្ឋ និងមាតុភូមិកម្ពុជាសព្វថ្ងៃ អោយចាកចេញពីអំណាចតាមរយៈការបោះឆ្នោតគ្រប់ជាន់ថ្នាក់ និងគ្រប់កាលៈទេសៈកុំបីខាន ។

គណបក្សប្រជាធិបតេយ្យសេរី គោរពសិទ្ធិមនុស្ស និងមេដឹកនាំថ្មី មានឆន្ទៈ និងសមត្ថភាពជួយការពារកសាងកម្ពុជាអោយគង់វង្សរីកចំរើនជាក់ស្តែងឆាប់រហ័ស កំពុងឈរប្រជែងជាមួយគណបក្សកាន់អំណាច ដើម្បីជួយសង្គ្រោះមាតុភូមិ និងប្រជាពលរដ្ឋកម្ពុជាយើងហើយ ។

សូមកម្ពុជាជាទីស្នេហាដ៏ខ្ពង់ខ្ពស់ និងប្រជាពលរដ្ឋកម្ពុជាជាទីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅរួចចាកផុតពីភាពពិសពុលបាត់បង់ខូចខាតដ៏ធ្ងន់ធ្ងរ ហើយចាប់យកភាពគង់វង្ស រុងរឿងសម្បូរណ៍សប្បាយជាបន្ទាន់ ។

ភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៥

**ហត្ថលេខា**

**គង់ គាំ**

**សមាជិកព្រឹទ្ធសភា**

**អនុប្រធានគណបក្ស សម រង្ស៊ី**